ស.ផ.ក.ក.
COSECAM

សម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាជួញដូរ
និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងប្រទេសកម្ពុជា

## កំណត់ហេតុ

# កិច្ចប្រជុំប្រតិភូសម្ព័ន្ធអង្គការភូសេកាំ



ថ្ងៃទី២៧ តុលា ២០០៨

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>កំណត់ហេតុ</u>

## កិច្ចប្រជុំប្រតិភូសម្ព័ន្ធអង្គការកូសេកាំ

ឆ្នាំពីរពាន់ប្រាំបី ខែ តុលា ថ្ងៃទី ម្ភៃប្រាំពីរ នៅវេលាម៉ោង ប្រាំបីនិងសែសិបប្រាំនាទីព្រឹក នៅសាកលវិទ្យាល័យខេមរៈមានរៀបចំកិច្ចប្រជុំក្រុមប្រតិភូសម្ព័ន្ធអង្គការកូសេកាំ ក្រោមអធិបតីភាព លោក **ទូន វិចិត្រ** ប្រធានសម្ព័ន្ធអង្គការកូសេកាំ ជាប្រធានអង្គប្រជុំ។

### <u>*របៀបវារៈនៃកិច្ចប្រជុំ*</u>

១- ការបើកកិច្ចប្រជុំ និងកិច្ចស្វាគមន៍ និងការបង្ហាញពីគោលបំណងនៃការប្រជុំ

២- ការធ្វើបច្ចុប្បន្នភាពដោយសង្ខេបអំពីកម្មវិធី កូសេកាំ

- កម្មវិធីតស៊ូមតិ និង ស្រាវជ្រាវ
- កម្មវិធីស្តារនិតិសម្បទា និងសមាហរណកម្ម
- កម្មវិធីអភិវឌ្ឍន៍ស្ថាប័ននិងធនធានមនុស្ស

៣- ការធ្វើបច្ចុប្បន្នភាពដោយសង្ខេបអំពីគម្រោង CETHCam[1]

- ផ្នែកសម្របសម្រួលការងារអង្គការដៃគូ
- ផ្នែកសម្របសម្រួលបច្ចេកទេសគម្រោង
- កាបង្ហាញពីថវិការបស់សម្ព័ន្ធអង្គការកូសេកាំ និង កិច្ចការរដ្ឋបាល

៤- ការបង្ហាញដោយសង្ខេបពីសកម្មភាពការងារ និង គោលបំណងសុំចូលជាសមាជិកសម្ព័ន្ធ សមាជិកថ្មី

៥- កិច្ចពិភាក្សាដើម្បីផ្តល់ការគាំទ្រ និង បដិសេធចំពោះសមាជិកថ្មី

៦- ផ្សេងៗ និង បិទកម្មវិធី

[1] Creating a Legal & Sustainable Environment for Trafficked Human Beings from and in Cambodia

*របៀបវារៈទី១ :*

**ការបើកកិច្ចប្រជុំ និងស្វាគមន៍ និងការបង្ហាញពីគោលបំណងនៃការប្រជុំ**

ជាកិច្ចចាប់ផ្តើមនៃកិច្ចប្រជុំ លោក ទូន វិចិត្រ បានសំដែងមតិស្វាគមន៍ដល់អង្គប្រជុំទាំងមូលព្រមទាំងបានថ្លែងអំណរគុណដល់ សមាជិក សមាជិកា នៃអង្គប្រជុំទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតំលៃចូលរួមកិច្ចប្រជុំនៅថ្ងៃនេះ។ លោកមានប្រសាសន៍ថា នេះជាការជួបប្រជុំគ្នាសារជាថ្មីម្តងទៀត ក្រោយពីយើងបានបែកគ្នាអស់មួយរយៈពេលកន្លងមក។ លោក ទូន វិចិត្រ ក៏បានលើកឡើងពីផ្លាកសញ្ញារបស់សម្ព័ន្ធអង្គការកូសេកាំដែល មាន ន័យថា **ចង្កឹះមួយដើមយើងអាចកាច់បំបាក់បាន តែបើចង្កឹះមួយបាច់យើងកាច់មិនបាក់ទេ**[2] នេះជាបាវចនារបស់ សម្ព័ន្ធអង្គការកូសេកាំ វាឆ្លុះបញ្ចាំងថាសាមគ្គីនាំអោយមានជោគជ័យ បែកបាក់សាមគ្គីនាំអោយបរាជ័យ វាជាហេតុផលចម្បងដែលនាំអោយយើងបង្កើតសម្ព័ន្ធអង្គការកូសេកាំនេះឡើង។ លោកបានមានប្រសាសន៍ថាសម្ព័ន្ធ អង្គការកូសេកាំ ត្រូវបានបង្កើតឡើងនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០១ ដែលសម្របសម្រួលដោយ លោក John Vijghen ក្នុងនោះមានអង្គការស្ថាបនិកចំនួនបី គឺ ADHOC, CWCC និង CDP ដោយផ្តោតទៅលើការកេងប្រវ័ញ្ចទៅលើកុមារ ហើយក្រោយមកទៀត មានការវិវឌ្ឍន៍ទៅជាការកេងប្រវ័ញ្ចផ្លូវភេទការជួញដូរ និងទម្រង់ផ្សេងៗទៀត នៃការកេងប្រវ័ញ្ចទៅលើកុមារដែលយើងចូលរួមធ្វើអន្តរាគមន៍ផងដែរ។ ដោយមើលឃើញបញ្ហានេះ យើងបានសំរេចដាក់ឈ្មោះថា **សម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហា ជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទទៅលើកុមារក្នុងប្រទេសកម្ពុជា**។ សមាជិករបស់យើងបានកើនជារៀងរហូតចាប់ ពី ៥ → ៨ → ១២ → ១៥ → ១៨ → ២៣ → ២២ → ២០ ប៉ុន្តែថ្ងៃនេះ ឬថ្ងៃស្អែកចំនួននេះអាចឡើងទៅដល់ ២៥ ឬ ២៦ ទោះជាយ៉ាងណាក៏ដោយ ក៏សមាជិករបស់យើងមិនអនុញ្ញាតអោយលើសពី ៣០ អង្គការសមាជិកនោះទេ ដើម្បីធានាគុណភាពនៃការគ្រប់គ្រង។

គណៈកម្មការនាយកត្រូវជ្រើសរើសដោយការបោះឆ្នោតក្នុងរយៈពេល២ឆ្នាំម្តង នៅក្នុងចំណោមអង្គការសមាជិក។ គណៈកម្មការនេះតែងតែប្រជុំដើម្បីពិភាក្សាគ្នាអំពីគោលដៅ និងគោលនយោបាយ របស់សម្ព័ន្ធជារៀងរាល់បីខែម្តង តែបើក្នុងករណីពិសេសលេខាធិការដ្ឋានអាចអញ្ជើញអោយចូលរួមប្រជុំជាបន្ទាន់។ កាលពីមុន គណៈកម្មការនាយកមានទិសដៅពីរផ្សេងគ្នា ទីមួយ គឺៈ សម្ព័ន្ធអង្គការកូសេកាំ បង្កើតឡើងគ្រាន់តែជាលេខាធិការដ្ឋានដើម្បីគាំទ្រដល់អង្គការជាសមាជិក និង ទីពី គឺៈ បន្តការអភិវឌ្ឍន៍ដើម្បីបំពេញមុខងារជាអ្នកសម្របសម្រួល និងគាំទ្រដល់អង្គការជាសមាជិកដើម្បីកសាងសមត្ថភាព និងរកមូលនិធិពីខាងក្រៅ សំរាប់ធ្វើការសម្របសម្រួលដល់អង្គការជាសមាជិក។ អស់រយៈពេលពីរឆ្នាំក្រោយមកទៀត ទើបសំរេចយកមតិទីពីរជាទិសដៅរបស់សម្ព័ន្ធ។ អង្គការជាសមាជិករបស់សម្ព័ន្ធបានធ្វើការរួមគ្នា ហើយក៏សរសេរគម្រោងថវិកា ដើម្បីស្នើសុំទៅ

[2] The motto is: *"One stick breaks easy but a bunch of sticks is unbeakable"*

សហគមន៍អឺរ៉ុប ដោយសហការជាមួយសម្ព័ន្ធពីរផ្សេងទៀត គឺ សម្ព័ន្ធចាប់ដៃ និង Ockenden Cambodia គំរោង CETHCam នេះជាសមិទ្ធផលរួមគ្នារបស់សម្ព័ន្ធអង្គការកូសេកា។

លោកប្រធានសម្ព័ន្ធ ក៏បានអនុញ្ញាតអោយសិក្ខាកាមដែលមានវត្តមាននៅក្នុងកិច្ចប្រជុំ មានឱកាសបង្ហាញអំពី ឈ្មោះ តួនាទី អោយបានស្គាល់គ្នាទៅវិញទៅមក។ បន្ទាប់ពីបានបង្ហាញអំពីប្រវត្តិ ដោយសង្ខេបរបស់សម្ព័ន្ធអង្គការរួចមក លោក ទូន វិចិត្រ បានជំរាបជូនពីគោលបំណងរបស់កិច្ចប្រជុំថ្ងៃនេះគឺដើម្បីៈ

១. បង្ហាញពីបច្ចុប្បន្នភាពរបស់សម្ព័ន្ធអង្គការកូសេកា រយៈពេល ១០ ខែ កន្លងមក ជាពិសេសគំរោង CETHCam

២. ការបង្ហាញពីការសាកល្បងគម្រោង CCM

៣. ការណែនាំអោយស្គាល់ និង បង្ហាញបេក្ខភាពដែលសុំដាក់ពាក្យចូលជាសមាជិកសម្ព័ន្ធថ្មី

*__របៀបវារៈទី២__*

## I - __ការបង្ហាញគម្រោងកម្មវិធីតស៊ូមតិ និងស្រាវជ្រាវ ដោយ លោក កែវ សំអឿន__

លោក កែវ សំអឿន មន្ត្រីកម្មវិធីតស៊ូមតិ និង ស្រាវជ្រាវ បានបង្ហាញអំពីគំរោងកម្មវិធីតស៊ូមតិ និងស្រាវជ្រាវ ដែលមានដូចខាងក្រោមៈ

### ក_កម្មវិធីស្រាវជ្រាវ

**១- គម្រោងកាត់បន្ថយរំលោភសន្ធវៈលើកុមារ (Reduce Rape of Children)**

__**សកម្មភាពៈ**__

- ការប្រកាសរបាយការណ៍អំពី ការចូលរួមប្រមូលទិន្នន័យ ស្តីអំពី ការជួញដូរ និង រំលោភសេពសន្ធវៈ សំរាប់ឆ្នាំ ២០០៥ - ២០០៦
- បន្តចូលរួមក្នុងការប្រមូលទិន្នន័យសំរាប់ឆ្នាំ ២០០៧ - ២០០៨ ជាមួយ ECPAT[3] and NGO CRC[4] តាមរយៈអង្គការជាសមាជិក និង មិនមែនសមាជិក
- បានចុះកិច្ចព្រមព្រៀងជាមួយ ៣ បណ្តាញផ្សេងទៀត
- បានរៀបចំសិក្ខាសាលាស្តីអំពីការប្រមូលទិន្នន័យ
- បែងចែកការទទួលខុសត្រូវ និង តួនាទី របស់បណ្តាញអង្គការនីមួយៗ

[3] End Child Prostitution, Child Pornography and Trafficking in Children for Sexual Purposes
[4] NGO Group for the Convention on the Rights of the Child

**២- គម្រោងផ្តល់អំណាចផ្នែកសង្គមនិងសេដ្ឋកិច្ចដល់កុមាររងគ្រោះដោយការជួញដូរ និង ការកេងប្រវ័ញ្ច (Social and Economic Empowerment of Girls Victims of Trafficking & Exploitation Project, Girl Speak Out)**

**សកម្មភាព:**

- រៀបចំសិក្ខាសាលា ចំនួន ៥ លើកនៅរៀងរាល់ថ្ងៃអាទិត្យ នៅខែ មករា មីនា មិថុនា សីហា និង តុលា
- ចំនួនសមាជិកថ្មីបានជ្រើសរើសនៅខែ មករា អោយចូលរួមជាមួយសមាជិកចាស់ ដែលបច្ចុប្បន្ននេះ ចំនួនកុមារសរុបទាំងអស់ ២៨ នាក់
- ប្រធានបទនៅក្នុងវគ្គសិក្ខាសាលានីមួយៗរួមមាន: ជំនាញក្នុងការចរចារ ជំនាញក្នុងការនិយាយជាសាធារណ: ច្បាប់ជួញដូរថ្មីនៅក្នុងប្រទេសកម្ពុជា អនុសញ្ញាស្តីអំពីសិទ្ធិកុមារ ជំនាញក្នុងការសំរេចចិត្ត ក្រុមមិត្តអប់រំមិត្ត និង ជំនាញតស៊ូមតិ

**៣- គម្រោងសម្របសម្រួលគ្រប់គ្រងករណីជនរងគ្រោះដោយការជួញដូរ (Coordinated Case Management of Victims of Trafficking, CCM)** ទទួលមូលនិធិពី: គម្រោង CETHCam,

**សកម្មភាព:**

- រៀបចំតួនាទី និង ភារកិច្ចរបស់ទីប្រឹក្សា
- ការប្រកាសជ្រើសរើសទីប្រឹក្សា
- ការបង្កើត និង ការកែលំអឯកសារដែលទីប្រឹក្សាបានបង្កើត
- ការចុះទៅស្រាវជ្រាវអំពីទីតាំងសំរាប់បង្កើតគំរោងកម្មវិធី **CCM**

**៤- ការរៀបចំអោយមានការតាក់តែងច្បាប់ស្តីអំពី ទេសន្តរប្រវេសន៍ និង ការជួញដូរមនុស្ស (LMT[5])**

**សំនួរ:** តើ កូសេកាំ មានគម្រោងបន្តការប្រជុំ អនុគណ:កម្មការ តស៊ូមតិ ដើម្បីជំរុញអោយមានការបង្កើត Child Protection Policy?

**ចំលើយ:** លោក ទួន វិចិត្រមានប្រសាសន៍ថា ដោយផ្អែកលើការស្រាវជ្រាវកន្លងមកមានអង្គការ ៦០ ទៅ ៦៥% ដែលមានគោលនយោបាយការពារកុមារ ។ នេះជារឿង សំខាន់ដែលអង្គការធ្វើការជាមួយកុមារតែមិនមានគោលការណ៍ការពារកុមារ ។ ដូចនេះ យើងនឹងធ្វើការពិភាក្សា និងតាមដានថាតើយើងគួរមានការប្រជុំទៀត ឬ មួយ យ៉ាងណា ។

**សំណួរ:** តើលទ្ធផលកុមារដែលមកចូលរួមធ្វើសិក្ខាសាលា GSO យ៉ាងណាដែរ?

[5] Legislation of Migration and Trafficking

**ចំលើយ:** លោកស្រី កៅ សុខដែត មានប្រសាសន៏ថា កន្លងមកក្រុមកុមារទាំងនេះ យល់ដឹងច្រើនពីសិទ្ធិកុមារ ការជួញដូរ មានកុមារមួយចំនួនទៅបង្រៀនក្មេងដទៃទៀតបន្ត ដោយយើងអោយអ្នកគ្រូជាសាមីអង្គការជាអ្នកតាមដានអោយកុមារមានឆន្ទះចង់ផ្សព្វផ្សាយដល់តំបន់ដែលខ្លួនរស់នៅ និងមានកុមារខ្លះជាអ្នកដើរតួក្នុងការផ្សព្វផ្សាយបន្ត។

**សំណួរ:** តើ កូសេកាំចង់អនុវត្ត LMT ដោយខ្លួនឯង ឬ ជាអ្នកសម្របសម្រួល?

**ចំលើយ:** លោក ទូន វិចិត្រ មានប្រសាសន៏ថា នេះជាកម្មវិធីមួយថ្មីយើងកំពុងតែធ្វើការសិក្សាស្រាវជ្រាវពីសកម្មភាព ការងារអង្គការដែលធ្វើការពាក់ព័ន្ធក្រោយមកយើងនឹងគិតថា នឹងធ្វើអ្វីទៀត។ យើងផ្តល់ថវិកាអោយអង្គការដែលធ្វើការនេះទាក់ទងរឿងនេះឬ យ៉ាងណា?

## II- កម្មវិធិស្ថានិតិសម្បទា និង សមាហរណកម្ម (R & R)

លោកស្រី សៀ សុរិទ្យា បានបង្ហាញពីលទ្ធផលសំរេចបានរបស់ កម្មវិធីស្ថានីតិសម្បទា និង សមាហរណកម្មៈ

### ១. គម្រោងមូលនិធិអាហារូបករណ៍បណ្តុះបណ្តាលវិជ្ជាជីវៈសំរាប់ជនរងគ្រោះដោយសារការជួញដូរផ្លូវភេទ

- អ្នកទទួលផលចំនួន ១០ នាក់ ក្នុងចំណោម ៣១ ដែលបានដាក់ពាក្យសុំ បានចូលបណ្តុះបណ្តាលនៅអង្គការ CVCD[6] សំរាប់រយៈពេល ៨ ខែ។
- ក្នុងចំណោម ១០ នាក់ មាន ៤ នាក់ជាអ្នករៀនពូកែ ហើយអាចទៅធ្វើការរកចំណូលបានពី ៣០-១០០$
- ២ នាក់ ត្រូវបានCVCD ទទួលឱ្យធ្វើការជាមួយទទួលបានប្រាក់ខែ ពី៣០-៣៥ ដុល្លារ ក្នុងមួយខែ និងមានផ្តល់កន្លែងស្នាក់នៅ។

### ២. គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចដើម្បីគាំទ្រដល់ជនដែលត្រូវបានគេជួញដូរ និងជនដែលងាយរងគ្រោះ

| | |
|---|---|
| ចំនួនអ្នកដែលបានស្នើសុំការគាំទ្រ និងបានធ្វើសំភាសន៏ | ២៧៦ នាក់ |
| ចំនួនអ្នកទទួលផលដែលទទួលបានការគាំទ្រ | ៧៦ នាក់ |
| ចំនួនអ្នកទទួលផលដែលបានបោះបង់ចោលមុខរបរ | ៩ នាក់ |
| ចំនួនអ្នកទទួលផលដែលមុខរបរពួកកំពុងមានស្ថេរភាព | ៦៧ នាក់ |

- ចំណូលប្រចាំថ្ងៃជាមធ្យម : ៧.០០០ — ៤០.០០០ រៀល

[6] Cambodian Volunteers for Community Development

- ក្រៅពីទទួលបានប្រាក់ចំណូលប្រចាំថ្ងៃ  អ្នកទទួលផលមានលទ្ធភាពជួលជុលផ្ទះ  អោយកូនទៅរៀន មានប្រាក់ព្យាបាលជំងឺ មានសំភារៈគ្រប់គ្រាន់ និងធ្វើបដិភាគជាមួយសហគមន៍ ។

**សំណួរ:** តើមានលក្ខណៈជ្រើសរើសបែបណាខ្លះដើម្បីទទួលឱ្យអតិថិជនចូលរៀនបាន និងហេតុអ្វីមិនជ្រើសរើសទាំងអស់?

**ចំលើយ:** លោកស្រី សៀ សុវិទ្យា បានឆ្លើយតបថា យើងមានលក្ខណៈវិនិច្ឆ័យ និងគោលការណ៍ជ្រើសរើស និងធ្វើឡើងដោយមានការសំភាសន៍ អង្កេត និង មានការចូលរួមពីសមាជិកដែលជាដៃគូរ ។

**សំណួរ:** កន្លងមកមានអង្គការមួយចំនួន ជួយអតិថិជនរួចហើយ តែក្រោយពីការជួយមួយរយៈ មកពួកគាត់នៅតែវិលត្រឡប់ទៅធ្វើការនៅប្រទេសក្រៅទៀត តើនោះមកពីហេតុអ្វី?

**ចំលើយ:** សូមពិនិត្យមើលលក្ខណៈវិនិច្ឆ័យឡើងវិញ រួមទាំងយុទ្ធសាស្ត្រក្នុងការអនុវត្តផងដែរ ។

## III- កម្មវិធីអភិវឌ្ឍន៍ស្ថាប័ននិងធនធានមនុស្ស (IHRD)

កម្មវិធីអភិវឌ្ឍន៍ស្ថាប័ន និង ធនធានមនុស្សមានគម្រោងចំនួនបីគឺ:

**១- គម្រោងប៉ាន់ប្រមាណតម្រូវការបង្កើនសមត្ថភាពអង្គការក្នុងស្រុក** (Capacity Needs Assement of Local NGOs)

- វគ្គគ្រប់គ្រងស្ថាប័នៈ សិក្ខាកាម ១៨ នាក់ ក្នុងចំណោម ២៦ ត្រូវបានធ្វើការស្ទង់មតិ ដើម្បីកំណត់ប្រធានបទនៃវគ្គបណ្តុះ បណ្តាល ។
- វគ្គអនុវត្តគម្រោងៈ យើងបានធ្វើការអង្កេតជាមួយបុគ្គលិកកម្មវិធីចំនួន ២៥៨នាក់ របស់អង្គការចំនួន ១៨ នៅក្នុង ៦ ខេត្ត-ក្រុង។ របាយការណ៍លទ្ធផលនៃការប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាល នឹងបញ្ចប់នៅខែ ធ្នូ ២០០៨។

**២- កម្មវិធីបណ្តុះបណ្តាល** (Training Program) ទទួលមូលនិធិពី ANESVAD

- វគ្គជំនាញបច្ចេកទេស៣វគ្គបានផ្តល់ដល់សិក្ខាកាមរួមមានៈ ការគ្រប់គ្រងទំនាស់ និងជំនាញក្នុងការ ស៊ើបអង្កេតបទឧក្រិដ្ឋ ដែលសម្របសម្រួលដោយ CDRI[7] and CDP ។

***២.១- ការគ្រប់គ្រងអង្គការ:***

- សម្ព័ន្ធអង្គការកូសេកាំ សហការជាមួយសាកលវិទ្យាល័យបញ្ញាសាស្ត្រ នឹងផ្តល់វគ្គបណ្តុះបណ្តាលចំនួន ២ ឆ្នាំ គឺចាប់ពីឆ្នាំ ២០០៨ ដល់ ២០១០។

[7] Cambodia Development Resource Institute

- បានបង្កើតកម្មវិធីសិក្សាសម្រាប់ឆ្នាំទី២ដែលមាន៧មុខវិជ្ជារួមមាន: ភាពជាអ្នកដឹកនាំ ការគ្រប់គ្រង ការផ្លាស់ប្តូរ ការគ្រប់គ្រងគម្រោង និង ការចាត់ចែង និងគ្រប់គ្រងស្ថាប័ន បានរៀបចំជាមេរៀនហើយ ។ ចំណែកមុខវិជ្ជាដែលនឹងត្រូវរៀបចំមាន ការរៀបចំគម្រោងថវិកា ការគ្រប់គ្រងចំណាយ និង ការសរសេររបាយការណ៍ ។

### ២.២- វគ្គការអនុវត្តន៍គម្រោង

### ៣- កម្មវិធីក្រុមផ្តល់ប្រឹក្សាចិត្តសង្គម

- រៀបចំប្រជុំប្រចាំខែ គោលនយោបាយ និង ផែនការសកម្មភាព
- ចូលរួមវគ្គបណ្តុះបណ្តាលដែលរៀបចំឡើងដោយ ***SACP***[8] នៅ ***Angiang University***
- ក្រុមនេះនឹងក្លាយទៅជា សមាគមផ្តល់ប្រឹក្សាយោបល់ចិត្តសង្គម

**សំណួរ:** សិក្ខាកាមដែលមករៀន បើសិនជាគាត់ឈប់កណ្តាលវគ្គវិញតើ កូ សេ កាំ មានវិធានការណ៍យ៉ាងណា?

**ចំលើយ:** ជាដំបូងសាមីអង្គការ ដែលបញ្ជូនបុគ្គលិកមកត្រូវតែធ្វើកិច្ចសន្យាជាមួយបុគ្គលិកខ្លួនថារៀនចប់នឹងបន្តការងារជាមួយអង្គការទៀតក្នុងពេលកំនត់ណាមួយ ។ បើក្នុងករណីបុគ្គលិកឈប់ហើយទៅធ្វើការនៅអង្គការថ្មីដែល ជាសមាជិករបស់កូសេកាំដដែលនោះកូសេកាំ នឹងធ្វើការពិចារណាឡើងវិញ ។ ប៉ុន្តែបើសិនជាគាត់ចង់បង់លុយរៀនបន្តនោះត្រូវវិធានាថា រៀនហើយត្រូវយកទៅអនុវត្ត បើពុំនោះទេមិនត្រូវបានអនុញ្ញាតអោយរៀនបន្តឡើយ ។

**បញ្ជាក់ :** ការបណ្តុះបណ្តាលនេះមានលក្ខណៈពិសេស ដោយអាចសន្សំក្រេឌីត បន្តរៀនក៏រិតបរិញ្ញាប័ត្រនៅ ***PUC***[9] ដោយមិនទុកក្រេឌីតយូរពេក ។ ការបង្រៀនមានលក្ខណៈផ្សារភ្ជាប់ទ្រឹស្តីនឹងអនុវត្តន៍ និងរបៀបជាសិក្ខាសាលាផង ។

***របៀបវារៈទី៣:***

### ***ការបង្ហាញពីគម្រោង***

លោកស្រី សៀ សុវិទ្យា បានបង្ហាញពីសមិទ្ធផលសំរេចបានរបស់គម្រោងនេះរួមមាន:

- បានបង្កើតលក្ខខណ្ឌ និងគោលការណ៍សំរាប់ការដាក់សំណើ
- បានរៀបចំ Concept Note format, Proposal format

[8] Southeast Asia Child Protection- Angiang University in Vietnam
[9] PANNASATRA University of Cambodia

- អង្គការដែលបានផ្ញើ Concept Note និង Proposal មកគំរោង CETHCam មានចំនួន ២១ អង្គការ ។

លោកស្រីក៏បានបង្ហាញជូនដល់សិក្ខាកាមផងដែរថា ដំណើរការនៃការរៀបចំ Concept Note និង Propsal ចែកជា ៥ ដំណាក់កាល គឺ:

១. Special Case
២. Fast Track
៣. Normal Track:
៤. Renewed Concept Note
៥. Rejected Concept Note

បន្ទាប់ពីបទបង្ហាញរបស់លោកស្រី សៀ សុវិទ្យា រួចមក លោក *John* បានលើកឡើងពីប្រវត្តិរបស់អង្គការ កូសេកាំ និងមធ្យោបាយដ៏ល្អសំរាប់ធ្វើការជាមួយគ្នា គឺការយកបញ្ហាមកដាក់លើតុ ហើយនាំគ្នាដោះស្រាយ ។ *John* បានជំរុញអោយអង្គការដែលជាសមាជិករួមចំណែកក្នុងការជួយដល់អ្នករងគ្រោះតាមរយៈប្រព័ន្ធ ហើយការ ធ្វើធ្វើសហប្រតិបត្តិការជាមួយរដ្ឋាភិបាលមានសារៈសំខាន់ខ្លាំងណាស់ក្នុងការបង្កើតអោយមានយន្តការ និងការសាកល្បងគំរោងកម្មវិធីសន្និសីទករណីនេះ ។ លោកបានបន្ថែមទៀតថា ប្រសិនបើអង្គការដែលជាសមាជិកត្រូវការជំនួយបច្ចេកទេស សូមធ្វើការទំនាក់ទំនងមកលោក ជុំ ផល្លី ដែលមានលេខទូរសព្ទ័ និង អ៊ីមែលចែកជូនស្រាប់ ។

លោក ជុំ ផល្លី មន្រ្តីសម្របសម្រួលបច្ចេកទេសគម្រោងបានធ្វើបទអន្តរាគមន៍ស្តីអំពី គំរោងសំរបសំរួលបច្ចេកទេសដូចខាងក្រោមនេះ:

- បានសហការណ៏ជាមួយក្រុមការងារពិសេសនៅថ្នាក់ជាតិ
- ពង្រឹងយន្តការ ការពារ
- សិក្សាស្វែងយល់អំពីខេត្តដែលមានសក្តានុពលក្នុងការសាកល្បង CCM
- ជួបប្រជុំជាមួយ UNICEF, Friend International, SCN[10], SCA[11] ស្តីអំពីប្រព័ន្ធគ្រប់គ្រងថ្នាក់ជាតិ

**<u>សំណួរ:</u>** តើការអនុវត្ត និងប្រព័ន្ធដែលមានស្រាប់មួយណាលឿនជាង និងរីកចំរើនជាង?

**<u>ចំលើយ:</u>** មិនច្បាស់នៅឡើយទេ យើងនឹងមានគំរោងសាកល្បង នៅខេត្តណាមួយសិន ។

**<u>សំណួរ:</u>** តើ កូសេកាំ ចង់ធ្វើការកែលំអ ឬ មួយចង់ផ្លាស់ប្តូរនៅអ្វីដែលគេមានស្រាប់?

[10] Save the Children Norway-Cambodia
[11] Save the Children Australia

**ចំលើយ:** លោក ទូន វិចិត្រ បានបញ្ជាក់ពីជំហានទាំង ១០ របស់ CCM និងឆ្លើយតបទៅនឹងសំនួរថា វាគ្រាន់តែជាការសិក្សាបន្ថែម និងធ្វើការកែលំអអោយប្រសើរជាងមុន។ យើងកំពុងតែធ្វើការសិក្សា ខេត្តដែលអាចធ្វើការសាកល្បងពី CCM នេះនៅខេត្ត សៀមរាប បាត់ដំបង ឬ បន្ទាយមានជ័យ និងបន្ទាប់មកទើបចំលងករណីជោគជ័យបន្តទៅខេត្ត ដទៃទៀត។

**បញ្ជាក់ :** អង្គការណាកាន់តែមានការសហការ ឱកាសទទួលថវិកាពី កូ សេ កាំ កាន់តែច្រើន។

***របៀបវារៈទី៤:***

***ការបង្ហាញពីថវិការបស់អង្គការកូសេកាំ និង កិច្ចការរដ្ឋបាល ផ្នែកគណនេយ្យ***

- ធ្វើរបាយការណ៏ប្រចាំខែ ឆមាស និង ប្រចាំឆ្នាំ សំរាប់ម្ចាស់មូលនិធិ
- រៀបចំអោយមានកិច្ចព្រមព្រៀង
- រៀបចំ និង សម្របសម្រួលវគ្គបណ្តុះបណ្តាលអំពីគណនេយ្យដល់អង្គការសមាជិក
- បង្កើតអោយមានយន្តការ និង គោលនយោបាយសំរាប់ប្រព័ន្ធហិរញ្ញវត្ថុ
- រៀបចំគោលការណ៏សំរាប់គំរោង CETHCam និង កញ្ចប់ថវិកា ២០០៨ - ២០១០

***ផ្នែករដ្ឋបាល***

- សម្របសម្រួលការងាររដ្ឋបាលរបស់សម្ព័ន្ធ គាំទ្រដល់សកម្មភាពនៃកម្មវិធីទាំង៤របស់សម្ព័ន្ធ ។
- សម្របសម្រួល និងទំនាក់ទំនងផ្ទាល់ជាមួយអង្គការជាតិ និងអន្តរជាតិ ដូចជា ការប្រជុំ សិក្ខាសាលា សំណើសុំថវិការបស់អង្គការជាសមាជិក... លិខិតសុំចូលជាសមាជិក(សមាជិកថ្មី) ការផ្សព្វផ្សាយ និងចែករំលែកពតិមានឱ្យគ្នាទៅវិញទៅមក។
- រៀបចំកិច្ចការរដ្ឋបាលផ្ទៃក្នុងរបស់សម្ព័ន្ធឱ្យមានភាពល្អប្រសើរ ដូចជា ការរៀបចំទុកដាក់ ឯកសារ និងរៀបចំប្រព័ន្ធទំនាក់ទំនងផ្ទៃក្នុង ។
- សម្របសម្រួលបង្កើតឱ្យមានវេបសាយ អ៊ីម៉ែល ឬព្រឹត្តិបត្រ .........។
- ចូលរួមរៀបចំបង្កើតគោលនយោបាយបុគ្គលិក ។ល។

ការធ្វើបច្ចុប្បន្នភាពរបស់គម្រោងកម្មវិធីនិមួយៗ បានចប់សព្វគ្រប់ទៅតាមពេលវេលាដែលបានគ្រោងទុក ហើយ សមាជិក សមាជិកា របស់អង្គប្រជុំទាំងមូលបានអញ្ជើញទៅពិសារភោជនីយហារនៅអាណាណា។

នៅពេលវេលាម៉ោងមួយនិង សាមសិបនាទីរសៀល អង្គប្រជុំបានចាប់ផ្តើមដំណើរការប្រជុំរបស់ខ្លួនដោយមានបទបង្ហាញរបស់អង្គការដែលបានដាក់ពាក្យសុំចូលជាសមាជិកថ្មីរបស់សម្ព័ន្ធអង្គការកូសេកា ដែលក្នុងនោះរួមមាន:

- អង្គការម្លប់តាប៉ាង M'lop Tapang
- អង្គការវីស៊ីអេអូ VCAO[12]
- អង្គការដំណក់ទឹកប៉ោយប៉ែត Goutte d'Eau Poi Pet
- អង្គការមាតុភូមិកុមារ MPK[13]
- អង្គការខារ៉ាមកម្ពុជា CARAM[14] Cambodia
- អង្គការផ្ទះរបស់យើង OUR HOME

### ១. អង្គការម្លប់តាប៉ាង

ម្លប់តាប៉ាងត្រូវបានបង្កើតឡើងនៅថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៣ ហើយចុះបញ្ជីក្នុងក្រសួងមហាផ្ទៃនៅ ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៣។ ក្រុមគោលដៅរបស់អង្គការម្លប់តាប៉ាងគឺៈ កុមារតាមផ្លូវ គ្រប់ប្រភេទកុមារ និងយុវវ័យដែលប្រើប្រាស់គ្រឿងញៀន កុមារអនាថា គ្មានទីពឹង កុមារត្រូវបានជួញដូរ និងរំលោភបំពាន ព្រមទាំងក្រុមគ្រួសារ និងសហគមន៍របស់ពួកគេ។ អង្គការនេះធ្វើសកម្មភាពសំខាន់ៗពីរគឺៈ សកម្មភាពនៅក្នុងមជ្ឈមណ្ឌល និងសកម្មភាពនៅតាមមូលដ្ឋាន។ សកម្មភាពនៅតាមមណ្ឌលរួមមាន ៧ មណ្ឌលគឺៈ

- មណ្ឌលអប់រំ ឬមណ្ឌលថែទាំពេលថ្ងៃ
- មណ្ឌលស្នាក់នៅកុមារា
- មណ្ឌលអប់រំសហគមន៍ (២)
- ក្លិបតាប៉ាង(មជ្ឈមណ្ឌលសិល្បៈ)
- មណ្ឌលអប់រំជំនាញវិជ្ជាជីវៈសំរាប់កុមារី និង កុមារា (២)
- មណ្ឌលសំចត

ចំណែកឯសកម្មភាពតាមសហគមន៍វិញ ក្រុមចុះតាមមូលដ្ឋានរបស់អង្គការម្លប់តាប៉ាង បានចុះធ្វើសកម្មភាពជារៀងរាល់ថ្ងៃនៅគ្រប់តំបន់គោលដៅសំខាន់ៗ ទាំងក្នុងសហគមន៍ តាមផ្លូវ និងនៅតាមមាត់សមុទ្រ ដូចជាៈ

[12] Vulnerable Children Assistance Organization
[13] Meatophume Komar (Homeland)
[14] Coordination of Action Research on AIDS and Mobility

ការថែទាំសុខភាពបឋម ការអប់រំសុខភាព ការអប់រំអំពីជំងឺអេដស៍ គ្រោះថ្នាក់នៃគ្រឿងញៀន របៀបការពារខ្លួនពីការរំលោភបំពានផ្សេងៗ និងផ្តល់អោយកុមារទាំងនោះ នូវជំរើសថ្មី សំរាប់ជីវិត របស់ពួកគេ។

### ២. អង្គការវីស៊ីអេអូ

អង្គការ វីស៊ីអេអូ ជាអង្គការក្នុងស្រុកមួយដែលបានបង្កើតឡើងនៅថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៤ ដោយ ក្រុមកុមារកំព្រាក្រោយសម័យប៉ុលពត ដែលបានគិតគូរអំពីទុក្ខកង្វល់របស់កុមារដែលត្រូវបានគេបោះបង់ចោល និងគ្មានផ្ទះសំបែង ហើយសង្គមរបស់ពួកគេក៏បោះបង់ចោលពួកគេចោលដែរ។ ដោយសារតែភាពក្រីក្រ កុមារទាំងនោះងាយនឹងរងគ្រោះដោយការកេងប្រវ័ញ្ចកំលាំងពលកម្ម ការជួញដូរផ្លូវភេទ។ លើសពីនេះទៀត កុមារទាំងនោះត្រូវគេបង្ខំអោយក្លាយជាអ្នករកស៊ីផ្លូវភេទដើម្បីចិញ្ចឹមជីវិត ដែលជាហេតុធ្វើអោយពួកគេងាយនឹងរងគ្រោះដោយសារជំងឺ អេដស៍ និង មេរោគអេដស៍។

អង្គការ វីស៊ីអេអូ ប្រតិបត្តិគម្រោងការងាររបស់ខ្លួននៅ ៥ ខេត្តក្រុង គឺៈ ភ្នំពេញ ខេត្តសៀមរាប ខេត្តតាកែវ កំពង់ចាម និង ខេត្តកំពង់ឆ្នាំង ដែលរួមមាន ១០ គំរោងកម្មវិធីៈ

១. គំរោងលុបបំបាត់អំពើហិង្សា ការរំលោភបំពានផ្លូវភេទ និង ការជួញដូរ និង កេងប្រវ័ញ្ចនៅតាមភូមិ
២. គំរោងលើកកំពស់ការទទួលបានការអប់រំថ្នាក់មូលដ្ឋាន
៣. គំរោងជំនាញការងារសហគមន៍
៤. គំរោងមជ្ឈមណ្ឌលសំរាប់ការអភិវឌ្ឍន៍ បំណិនជីវិត និង ក្តីសង្ឃឹម
៥. គំរោងការជួយគាំទ្រដល់កុមារដែលបំរើការងារតាមផ្ទះ
៦. គំរោងស្នេហភាពសង្គម
៧. គំរោងការសន្សំ និង ការបង្វិលប្រាក់
៨. គំរោងការតស៊ូមតិសិទ្ធិកុមារ
៩. គំរោងគ្រប់គ្រងពត៌មាន និង វាយតំលៃកម្មវិធី
១០.គំរោងអភិវឌ្ឍន៍អង្គការ និង កសាងសមត្ថភាព

### ៣. អង្គការដំណក់ទឹកប៉ោយប៉ែត

ដំណក់ទឹកប៉ោយប៉ែតត្រូវបានផ្តួចផ្តើមដោយអង្គការតំណក់ទឹកស្វីស អង្គការ UNICEF និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅក្នុងឆ្នាំ១៩៩៩ ដើម្បីជួយដល់កុមារដែលរងគ្រោះងាយនឹងរងគ្រោះ និងជួយទៅដល់ក្រុមគ្រួសាររបស់គេ។ អង្គការនេះបានចុះឈ្មោះជាអង្គការជាតិនៅក្រសួងមហាផ្ទៃក្នុង

ឆ្នាំ២០០៤ បានចុះអនុស្សារណៈជាមួយ ស ក ប យ លើកទី១ក្នុងឆ្នាំ២០០៥ និងបានបន្តសំរាប់រយៈពេល ៣ឆ្នាំទៀត កាលពីដើមឆ្នាំ២០០៨នេះ ។

ដំណាក់ទឹកប៉ោយប៉ែតបានផ្តល់សេវាកម្មដល់កុមារ ៤០០ នាក់ក្នុង ១ ថ្ងៃ ដោយបាននិងកំពុងអនុវត្ត គំរោងកម្មវិធីដូចជា: មណ្ឌលស្នាក់នៅបណ្តោះអាសន្ន មណ្ឌលស្តារនីតិសម្បទា មណ្ឌលទទួលមណ្ឌលស្នាក់នៅ និង មណ្ឌលអប់រំក្រៅប្រព័ន្ធ គ្លីនិក កម្មវិធីផលិតទឹកស្អាត និងកម្មវិធីសាលារដ្ឋ។

## ៤. អង្គការមាតុភូមិកុមារ

អង្គការមាតុភូមិកុមារ ជាអង្គការក្នុងស្រុកមួយដែលបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៧ ហើយបានចុះឈ្មោះជាមួយក្រសួងមហាផ្ទៃ និងអនុស្សរណៈជាមួយ MoSAVY។ អង្គការមាតុភូមិកុមារធ្វើសកម្មភាពរបស់ខ្លួនជាមួយកុមារអនាថា កុមារដែលត្រូវគេជួញដូរ កុមារដែលទទួលរងគ្រោះដោយសារការរំលោភបំពានផ្លូវភេទ កុមារកំព្រា និងងាយរងគ្រោះដោយសារជំងឺអេដស៍ កុមារដែលមានអំពើហិង្សាក្នុងគ្រួសារ។ តំបន់គោលគោលដៅមាននៅក្នុងស្រុកបាត់ដំបង ស្រុកថ្មគោល ស្រុកឯកភ្នំ ស្រុកសំពៅលូន ស្រុកកំរៀង និងស្រុកបាណន់ ហើយនិងធ្វើសមាហរណកម្មទៅតាមខេត្តក្រុងនានា។

អង្គការមាតុភូមិកុមារមានកម្មវិធីធំៗចំនួន ៥ គឺ

១. ផ្លូវមិនមែនជាផ្ទះរបស់ខ្ញុំទេ

២. កុមារដែលរងគ្រោះមានស្ថានភាពល្អប្រសើរឡើងវិញតាមរយៈការថែទាំជំនួស

៣. មានមណ្ឌលសំរាប់ស្នាក់នៅ

៤. ផ្តល់ការថែទាំដល់កុមារកំព្រា ដែលក្រុមគ្រួសាររងផលប៉ះពាល់ដោយសារជំងឺអេដស៍ និង រ៉ាំរ៉ៃ និង រកប្រាក់ចំណូល

៥. ប្រឆាំងការជួញដូរកុមារ និង ស្ត្រី នៅភ្នំព្រឹក កំរៀង

## ៥. អង្គការខារ៉ាមកម្ពុជា

អង្គការ ខារ៉ាមកម្ពុជា ជាអង្គការដែលធ្វើការជាមួយទេសន្តប្រវេសន៍ ដើម្បីអោយផ្តល់អំណាច និង បង្កើន ចំណេះដឹងរបស់ពួកគេ និង ធ្វើការតស៊ូមតិដើម្បីលើកកំពស់ និងការពារសិទ្ធិរបស់ទេសន្តប្រវេសន៍។ អង្គការខារ៉ាម កម្ពុជាធ្វើសកម្មភាពសំខាន់ៗមួយចំនួនដូចជា: សិទ្ធិពលករ ការបណ្តុះបណ្តាលអំពីការការពារ មេរោគអេដស៍ និង ជំងឺអេដស៍ ការបណ្តុះបណ្តាលពលករមុនពេលចាកចេញ ការធ្វើសមាហរណកម្ម តស៊ូមតិ និងនៅមានបណ្តាញ នៅក្នុងតំបន់។

## ៦. អង្គការផ្ទះរបស់យើង

អង្គការផ្ទះរបស់យើងជាអង្គការក្នុងស្រុកមួយដែលបានបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៩ ធ្វើការជាមួយក្រុមកុមារដែលងាយរងគ្រោះ ការពារសិទ្ធកុមារពីការកេងប្រវ័ញ្ច ការជួញដូរ និងរំលោភបំពានគ្រប់ប្រភេទ ធ្វើយ៉ាងណា ដើម្បីអោយពួកគេបានចូលរួមក្នុងសកម្មភាពសង្គម និងអភិវឌ្ឍជំនាញសំរាប់អនាគតរបស់ពួកគេ។

អង្គការផ្ទះរបស់យើងមានសកម្មភាពជាច្រើនដូចជា: មានមណ្ឌល ៣ កម្មវិធីអាហារូបករណ៍ កម្មវិធីសុខភាពបឋម កម្មវិធីទឹកស្អាត និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

បន្ទាប់ពីការធ្វើបទបង្ហាញរបស់អង្គការនីមួយៗរួចមក គណៈកម្មការអចិន្ត្រៃយ៍បានសាកសួរអំពីការប្តេជ្ញាចិត្តក្នុងការចូលរួមជាមួយសម្ព័ន្ធអង្គការកូសេកាំ និងអង្គការដែលបានធានាអោយអង្គការទាំងនេះ។ អង្គការទាំង ៦ ដែលបានដាក់ពាក្យសុំចូលជាសមាជិក មានការប្តេជ្ញាចិត្តខ្ពស់ក្នុងការចូលរួមរាល់សកម្មភាពរបស់សម្ព័ន្ធ ដូចជាការប្រជុំ និង សកម្មភាពផ្សេងៗទៀត ដោយសង្ឃឹមថា ការចូលជាសមាជិករបស់សម្ព័ន្ធផ្តល់អត្ថប្រយោជន៍ជាច្រើនដល់អង្គការរបស់ខ្លួនដូចជា ការកសាងសមត្ថភាពរបស់បុគ្គលិក ការចែករំលែក និងរៀនសូត្រអំពីការងារទៅវិញទៅមករវាងអង្គការដែលជាសមាជិក និងការរួមសាមគ្គីគ្នាអោយមានសំឡេងកាន់តែខ្លាំងក្នុងការធ្វើការតស៊ូមតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរ ការកេងប្រវ័ញ្ច និងការរំលោភបំពានទៅលើកុមាររាល់គ្រប់ទំរង់ផ្សេងៗ។

ក្រោយពីបានស្តាប់បទបង្ហាញរបស់អង្គការទាំង ៦ ដែលបានសុំដាក់ពាក្យជាសមាជិកថ្មីរបស់សម្ព័ន្ធរួចមក អង្គការដែលជាសមាជិកអចិន្ត្រៃយ៍សំរេចចិត្តបោះឆ្នោតដោយយករូបមន្ត ៥០ បូក ១។ ក្រោយពីពិភាក្សាអំពីការងារសកម្មភាពរបស់អង្គការនីមួយៗ សមាជិកអចិន្ត្រៃយ៍បានសំរេចចិត្តយកបេក្ខភាពអង្គការចំនួន ៥ មកបោះឆ្នោតដោយឡែក អង្គការផ្ទះរបស់យើង សមាជិក សមាជិកា សំរេចចិត្តព្យួរបេក្ខភាពនេះទៅលើកក្រោយសិន ដោយសារមិនទាន់បានចុះទៅពិនិត្យដល់កន្លែងដែលអង្គការនេះកំពុងធ្វើការ។ នៅក្នុងចំណោមអង្គការសមាជិកទាំង ១១ ដែលបានចូលរួមក្នុងកិច្ចប្រជុំនោះបានសំរេចឯកភាពបោះឆ្នោតអោយអង្គការទាំង ៥ ចូលជាសមាជិកថ្មីរបស់សម្ព័ន្ធ។

| ឈ្មោះអង្គការ | ចំនួនគាំទ្រ |
|---|---|
| M'LOP TAPANG | ១១ សំឡេង លើ១១ សំឡេង |
| VCAO | ១១ សំឡេង លើ១១ សំឡេង |
| Goutte d’Eau Poi Pet | ១១ សំឡេង លើ១១ សំឡេង |
| MPK | ១១ សំឡេង លើ១១ សំឡេង |
| CARAM Cambodia | ១១ សំឡេង លើ១១ សំឡេង |
| OUR HOME | **ព្យួរបេក្ខភាព** |

ជាកិច្ចបញ្ចប់កម្មវិធី លោក ទូន វិចិត្រ ប្រធានសម្ព័ន្ធអង្គការកូសេកាំ បានថ្លែងអំណរគុណ ចំពោះសមាជិក សមាជិកា ទាំងអស់ដែលបានចំណាយពេលវេលាចូលរួមក្នុងកិច្ចប្រជុំនៅថ្ងៃនេះ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោងប្រាំនិងដប់ប្រាំនាទីនាថ្ងៃដដែលនោះ ក្រោមបរិយាកាសរីករាយ និង ស្និទ្ធស្នាលបំផុត។

# សមាសភាពអ្នកចូលរួម

# កិច្ចប្រជុំគណៈប្រតិភូសម្ព័ន្ធអង្គការកូសេកាំ

# ថ្ងៃទី ២៧ តុលា ២០០៨

| | | |
|---|---|---|
| ១- | លោក ទូន វិចិត្រ | ប្រធានសម្ព័ន្ធអង្គការកូសេកាំ (ជាប្រធានអង្គប្រជុំ) |
| ២- | លោក ចន វីហ្គេន | ទីប្រឹក្សាសម្ព័ន្ធអង្គការកូសេកាំ និង គម្រោង CETHCam |
| ៣- | កញ្ញា មាស សូលីដា | ជំនួយការផ្នែកច្បាប់ LSCW |
| ៤- | លោកស្រី ម៉ៅ ឡាង | នាយិកា Homeland |
| ៥- | លោកស្រី អ៊ិម ស្រីលាប | ជំនួយការផ្នែកច្បាប់ PJJ |
| ៦- | លោកស្រី ស៊ិន លីពៅ | មន្ត្រីកម្មវិធីអង្គការ CWCC |
| ៧- | លោក សំ សុវណ្ណារិទ្ធិ | នាយកប្រតិបត្តិ Goutte d'Eau Naekloeung |
| ៨- | លោក គង់ សុភា | នាយកប្រតិបត្តិ KnK |
| ៩- | លោក សេង សុទ្ធាវុធ | រដ្ឋបាល CCPCR |
| ១០- | លោក ប៊ុន ទិត្យារិទ | មន្ត្រីគ្រប់គ្រងមណ្ឌល PTD |
| ១១- | លោក អ៊ឹង សុក្ខាន់ | ប្រធានគំរោងកម្មវិធី RCF |
| ១២- | លោក ឡុង សិរីទ្ធី | អ្នកសំរបសំរួល DTPPT |
| ១៣- | លោក ពុំ រាត្រី | អ្នកគ្រប់គ្រងទូទៅ CHO |
| ១៤- | លោក ឈន រាសី | ប្រធានរដ្ឋបាល LSCW |
| ១៥- | លោក កែវ សេរី | ប្រធានគណនេយ្យ CCASVA |
| ១៦- | កញ្ញា វង្ស ឆវី | ជំនួយការគណនេយ្យ WP |
| ១៧- | លោកស្រី នុត ណាង | អនុប្រធានការិយាល័យមន្ទីរសង្គមកិច្ចរាជធានីភ្នំពេញ |
| ១៨- | លោកស្រី ហ៊ុន ផាណ្ណា | ជំនួយការនាយកប្រតិបត្តិ CWDA |
| ១៩- | លោក ជា ពីដែន | នាយកប្រតិបត្តិ VCAO |
| ២០- | លោក មាស សារ៉េត | ប្រធានកម្មវិធី CARAM Cambodia |
| ២១- | កញ្ញា ប៉ែន លក្ខិណា | មន្ត្រីកម្មវិធី WVC |
| ២២- | លោក អ៊ីវ សៅសារីន | នាយកប្រតិបត្តិ M'lop Tapang |
| ២៣- | កញ្ញា អ៊ុំ មុំម៉ារី | គណនេយ្យករ សម្ព័ន្ធអង្គការកូសេកាំ |

| | | |
|---|---|---|
| ២៤- | លោក សុក សុធន | មន្ត្រីជំនួយការផ្នែកសម្របសម្រួលបច្ចេកទេសគំរោងសម្ព័ន្ធកូសេកាំ |
| ២៥- | លោក ឯម ពូល | មន្ត្រីកម្មវិធី អភិវឌ្ឍន៏ស្ថាប័ន និង ធនធានមនុស្ស សម្ព័ន្ធកូសេកាំ |
| ២៦- | លោកស្រី សៅ សុវិទ្យា | ប្រធានផ្នែកសម្របសម្រួលការងារអង្គការជាដៃគូ សម្ព័ន្ធកូសេកាំ |
| ២៧- | លោក កែវ សំអឿន | មន្ត្រីកម្មវិធីតស៊ូមតិ និង ស្រាវជ្រាវ សម្ព័ន្ធអង្គការកូសេកាំ |
| ២៨- | លោក ថោង ភិរម្យ | ប្រធានរដ្ឋបាល សម្ព័ន្ធអង្គការកូសេកាំ |
| ២៩- | លោក ជុំ ផល្លី | មន្ត្រីសម្របសម្រួលបច្ចេកទេសគំរោង សម្ព័ន្ធអង្គការកូសេកាំ |
| ៣០- | លោក ង៉ែត សុភាព | មន្ត្រីជំនួយការផ្នែករដ្ឋបាល សម្ព័ន្ធអង្គការកូសេកាំ |
| ៣១- | អ្នកស្រី ព្រុំ ផលឌីន | ជំនួយការកម្មវិធីស្ថានិតិសម្បទា និងសមាហរណកម្ម សម្ព័ន្ធកូសេកាំ |
| ៣២- | អ្នកស្រី កៅ សុខដែត | ជំនួយការកម្មវិធីអភិវឌ្ឍន៏ស្ថាប័ន និងធនធានមនុស្ស សម្ព័ន្ធកូសេកាំ |
| ៣៣- | លោក ចាន់ ប៊ុណ្ណារ៉ា | អនុប្រធានផ្នែកសម្របសម្រួលការងារអង្គការជាដៃគូ សម្ព័ន្ធកូសេកាំ |
| ៣៤- | លោក នី កែវប៉ុញ្ញា | មន្ត្រីទំនាក់ទំនងសាធារណះ សម្ព័ន្ធអង្គការកូសេកាំ |
| ៣៥- | លោក ប៊ុត ឫទ្ធី | ប្រធានផ្នែកហិរញ្ញវត្ថុ សម្ព័ន្ធអង្គការកូសេកាំ |

**ភ្នំពេញ ថ្ងៃទី ២៧ តុលា ២០០៨**

ធ្វើកំណត់ហេតុដោយលោក កែវ សំអឿន

ជំនួយការដោយ លោកស្រី ព្រុំ ផលឌីន និង លោកស្រី

កៅ សុខ ដែត